Khmer

# ហេតុអ្វីបានជាកូនរបស់ខ្ញុំត្រូវចូលកម្មវិធីមត្តេយ្យសាលា?



ការរៀននៅបឋមវ័យគឺមានសារសំខាន់ណាស់។ វាធ្វើឲ្យមានអនុភាពលើក្មេងក្នុងការអប់រំ ការងារហើយនិងជីវិតនៅថ្ងៃក្រោយ។ អ្វីៗដែលកើតមានដល់ក្មេងម្នាក់នៅបឋមវ័យអាចប៉ះពាល់ដល់របៀបដែលខួរក្បាលគេលូតលាស់។

នៅរដ្ឋវិចតូរិយ៉ា រដ្ឋាភិបាលផ្តល់ប្រាក់សំរាប់ក្មេងម្នាក់ៗដើម្បីចូលមត្តេយ្យសាលាក្នុងពេលមួយឆ្នាំ។ តាមធម្មតានេះគឺមួយឆ្នាំមុនក្មេងចាប់ផ្តើមចូលសាលារៀន។ កម្មវិធីសាលាមត្តេយ្យសាលាអាចមាននៅតាមមត្តេយ្យសាលាសហគមន៍ មជ្ឈមណ្ឌលថែរក្សាកុមារ ឬតាមសាលារៀនខ្លះ។

មត្តេយ្យសាលាទាំងអស់ដែលបានទទួលប្រាក់នោះនឹងដាក់តាំង kindergarten certificate (សូមមើលទំព័រម្ខាងទៀត) ហើយមានគ្រូដែលមានជំនាញខាងបឋមវ័យនៃកុមារភាព។

## ព័ត៌មានបន្ថែមទៀត

ចំពោះព័ត៌មានថែមទៀតស្តីពីកម្មវិធីមត្តេយ្យសាលានិងសេវាដទៃទៀតសំរាប់ក្មេងនៅក្នុងតំបន់លោកអ្នក សូមទាក់ទងនឹងរដ្ឋាភិបាលតំបន់របស់លោកអ្នក ឬការិយាល័យនៃក្រសួងកិច្ចបំរើមនុស្សតាមតំបន់លោកអ្នក។ លោកអ្នកក៏អាចរកបាននូវព័ត៌មានថែមទៀតដែរដោយទាក់ទងសាខានៃសេវាបឋមវ័យនៅក្នុងការិយាល័យសំរាប់កុមារតាមលេខ 1300 731 947 ឬបើកមើលវែបសៃរបស់ក្រសួងកិច្ចបំរើមនុស្សគឺ
**www.dhs.vic.gov.au/earlychildhood**

## បទពិសោធន៍ដ៏ទូលំទូលាយ

កម្មវិធីមត្តេយ្យសាលានឹងផ្តល់ឲ្យកូនលោកអ្នកនូវបទពិសោធន៍ជាច្រើនប្រភេទ។ បទពិសោធន៍ទាំងឡាយជួយកូនលោកអ្នកឲ្យលូតលាស់និងចេះដឹងគ្រប់វិស័យទាំងអស់។ អ្នកខ្លះគេហៅករណីនេះថា ការប្រុងស្មារតីទៅលើ "កូនទាំងស្រុង"។

ក្នុងចំណោមអ្វីៗដទៃទៀត កូនលោកអ្នកនឹង៖

- ប្រើភាសា
- ចុះផ្លុងនឹងក្មេងដទៃទៀត
- ប្រាកដក្នុងខ្លួន
- គូរ លាបពណ៌ ច្រៀងនិងរាំ
- រក រុករកនិងដោះស្រាយបញ្ហានានា។

កូនលោកអ្នកនឹងរៀនអំពី

- ខ្លួនគាត់ ឬខ្លួនឯង
- អ្នកដទៃ
- ពិភពលោក។

កូនលោកអ្នកក៏នឹងរៀនអំពីជំនាញការនិងរកព័ត៌មានដែលជួយគេឲ្យទៅជាអ្នកអាននិងជាអ្នកនិពន្ធដ៏ល្អម្នាក់។

## ការរៀននៅជាមួយអ្នកដទៃ

កូនលោកអ្នកនឹងរៀនរបៀបចុះផ្លុងនឹងក្មេងដទៃទៀតដោយ

- ថែរក្សានិងចិត្តល្អ
- ភាពវិជ្ជមានលើអ្នកដែលមិនដូចខ្លួន
- បង្ហាញនូវអារម្មណ៍ក្នុងផ្លូវល្អ
- ជួយអ្នកដទៃនិងរកជំនួយពីអ្នកដទៃ
- រៀនរបៀបល្អដើម្បីដោះស្រាយការប៉ះទង្គិចគ្នា
- ធ្វើការជាមួយអ្នកដទៃដើម្បីឲ្យកិច្ចការបានសម្រេច។

## កូនជាបុគ្គលម្នាក់

គ្រូខាងបឋមវ័យនៃកុមារភាពនឹងរៀនអំពីកូនរបស់លោកអ្នក។ គេនឹងស្គាល់លោកអ្នកហើយនិងគ្រួសាររបស់លោកអ្នក និងរៀនអំពីវប្បធម៌និងសហគមន៍របស់លោកអ្នក។ គ្រូនេះនឹងមើលឃើញនូវកម្លាំង ការចាប់អារម្មណ៍ ការប៉ិនប្រសប់និងសេចក្តីត្រូវការរបស់កូនលោកអ្នក។ កូនលោកអ្នកនឹងត្រូវគេមើលឃើញថាជាជនពិសេសម្នាក់ មិនមែនដូចជនដទៃណាម្នាក់ទេ។

## ការគាំទ្រមាតាបិតា

លោកអ្នកនឹងមានឱកាសស្គាល់មាតាបិតាដទៃទៀត។ លោកអ្នកអាចពិភាក្សាជាមួយគ្រូនិងរកការគាំទ្រសំរាប់កង្វល់ទាំងឡាយណាអំពីកូនលោកអ្នក។ កូនលោកអ្នកនឹងរៀនបានល្អនៅមត្តេយ្យសាលា នៅពេលលោកអ្នកប្រាប់បុគ្គលិកឲ្យដឹងថាលោកអ្នកចង់បានអ្វីហើយថាតើលោកអ្នកយល់ឃើញកូនលោកអ្នកយ៉ាងណាផងដែរ។

មត្តេយ្យសាលាក៏ជួយរកមូលហេតុ ប្រសិនបើក្មេងត្រូវការជំនួយបន្ថែមទៀត។ កម្មវិធីមត្តេយ្យសាលាមានការទាក់ទងជាមួយនឹងជំនួយច្រើនប្រភេទផ្សេងៗទៀត។

បុគ្គលិកអាចជួយលោកអ្នក ប្រសិនបើលោកអ្នកត្រូវការសេវាដទៃទៀតសំរាប់កូនលោកអ្នក គ្រួសារលោកអ្នក ឬលោកអ្នកខ្លួនឯង។

## មើលទៅអនាគតកាល

ក្មេងភាគច្រើននៅក្នុងកម្មវិធីមត្តេយ្យសាលានឹងចាប់ផ្តើមចូលរៀនឆ្នាំក្រោយបន្ទាប់មក។ មត្តេយ្យសាលាអាចជួយពួកគេឈានមួយជំហានទៅមុខដោយជោគជ័យ។ កាលណាក្មេងដឹងប្រាកដក្នុងខ្លួនឯង គេអាចទប់ទល់នឹងស្ថានការណ៍ថ្មីៗ។ សើរវាជាមួយកម្មវិធីមត្តេយ្យសាលាជាច្រើនធ្វើការជាមួយសាលាតាមតំបន់ដើម្បីជួយគ្រួសារនិងក្មេងទាំងឡាយផ្លាស់ប្តូរដោយងាយស្រួលពេលទៅសាលារៀន។

**ការិយាល័យសំរាប់កុមារ...ជួយគ្រួសារវិចតូរិយ៉ានានាឲ្យកូនគេនូវការចាប់ផ្តើមដ៏ល្អបំផុតនៃជីវិត។**

A Victorian Government initiative

Victoria The Place To Be

Department of Human Services

This document is managed by the Department of Education and Early Childhood Development, Victoria (as of 27 August 2007)

# វិញ្ញាបនប័ត្រមត្តេយ្យសាលា




**រកមើលវិញ្ញាបនប័ត្រនេះ នៅពេលជ្រើសរើសកម្មវិធីមត្តេយ្យសាលា ឬ ថែរក្សាកុមារសំរាប់កូនអាយុបួនឆ្នាំរបស់លោកអ្នក។**

វិញ្ញាបនប័ត្រមត្តេយ្យសាលាមានន័យថាកម្មវិធីមត្តេយ្យសាលានៅសេវានេះ ត្រូវបានផ្តល់ដោយគ្រូដែលមានជំនាញខាងបឋមវ័យនៃកុមារភាពហើយ បានផ្តល់ប្រាក់ដោយរដ្ឋាភិបាលរដ្ឋផង។ ដោយស្គាល់សារសំខាន់នៃបឋមវ័យនេះ រដ្ឋាភិបាលផ្តល់ប្រាក់សំរាប់ក្មេងម្នាក់ៗដើម្បីរៀនមួយឆ្នាំនៅក្នុងមត្តេយ្យសាលា។ តាមធម្មតា នេះគឺជាឆ្នាំមុនក្មេងចាប់ផ្តើមចូលសាលារៀន។

## ចំពោះព័ត៌មានថែមទៀត

ចំពោះព័ត៌មានថែមទៀតស្តីពីកម្មវិធីមត្តេយ្យសាលានៅតាមតំបន់លោកអ្នក សូមទាក់ទងនឹងរដ្ឋាភិបាល តំបន់លោកអ្នកតាមវែបសៃដូចតទៅនេះ

**www.mav.asn.au/**

**www.vicnet.net.au/government/localgovt**

សូមបើកមើលវែបសៃនៃការិយាល័យសំរាប់កុមារនៃបឋមវ័យគឺ – **www.dhs.vic.gov.au/earlychildhood**
ឬទូរស័ព្ទទៅសាខានៃសេវានៃបឋមវ័យនៅការិយាល័យសំរាប់កុមារតាមលេខ 1300 731 947 (តម្លៃទូរស័ព្ទតំបន់) ។

A Victorian Government initiative

Victoria The Place To Be

Department of Human Services

This document is managed by the Department of Education and Early Childhood Development, Victoria (as of 27 August 2007)